**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០២ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៤៣,៣១ ហិកតា នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៦៨ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពី គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៨៦៨ អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៤៣,៣១ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៤២,៤៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ០,៨៤ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិជ្រៃ ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៦៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅភូមិជ្រៃ ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៤ ស្តីពីការកាត់ឆ្វៀលដីទំហំ ៤៣,៣១ហិកតា នៅក្នុងស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៦៨គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ**







**តារាងចំណុចនិយាមកា**

| ID | X | Y | ID | X | Y | ID | X | Y | ID | X | Y | X | Y | Y | ID | X | Y | ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 446871 | 1242193 | 14 | 446535 | 1242287 | 27 | 446211 | 1242319 | 40 | 445993 | 1242445 | 53 | 445874 | 1242313 | 66 | 446183 | 1241939 | 79 | 446452 | 1241875 | 91 | 446840 | 1241897 | 103 | 446874 | 1242080 |
| 2 | 446619 | 1242349 | 15 | 446509 | 1242290 | 28 | 446159 | 1242329 | 41 | 445988 | 1242455 | 54 | 445874 | 1242305 | 67 | 446205 | 1241981 | 80 | 446558 | 1241975 | 92 | 446845 | 1241941 | 104 | 446877 | 1242095 |
| 3 | 446618 | 1242345 | 16 | 446492 | 1242294 | 29 | 446165 | 1242345 | 42 | 445988 | 1242466 | 55 | 445870 | 1242278 | 68 | 446289 | 1241988 | 81 | 446559 | 1241975 | 93 | 446841 | 1241942 | 105 | 446882 | 1242097 |
| 4 | 446619 | 1242344 | 17 | 446454 | 1242298 | 30 | 446170 | 1242359 | 43 | 445965 | 1242475 | 56 | 445886 | 1242275 | 69 | 446283 | 1241958 | 82 | 446614 | 1241996 | 94 | 446836 | 1241963 | 106 | 446886 | 1242096 |
| 5 | 446616 | 1242341 | 18 | 446408 | 1242306 | 31 | 446159 | 1242364 | 44 | 445952 | 1242477 | 57 | 445875 | 1242220 | 70 | 446282 | 1241869 | 83 | 446656 | 1241967 | 95 | 446836 | 1241984 | 107 | 446891 | 1242104 |
| 6 | [illegible] | 1242323 | 19 | 446405 | 1242282 | 32 | 446104 | 1242376 | 45 | 445942 | 1242437 | 58 | 445847 | 1242222 | 71 | 446296 | 1241870 | 84 | 446699 | 1241888 | 96 | 446827 | 1241991 | 108 | 446888 | 1242106 |
| 7 | 446602 | 1242283 | 20 | 446337 | 1242291 | 33 | 446075 | 1242384 | 46 | 445940 | 1242408 | 59 | 445801 | 1242077 | 72 | 446288 | 1241832 | 85 | 446718 | 1241789 | 97 | 446830 | 1242003 | 109 | 446885 | 1242118 |
| 8 | 446597 | 1242262 | 21 | 446320 | 1242293 | 34 | 446072 | 1242379 | 47 | 445939 | 1242385 | 60 | 445822 | 1241988 | 73 | 446328 | 1241818 | 86 | 446783 | 1241794 | 98 | 446846 | 1241993 | 110 | 446866 | 1242116 |
| 9 | 446581 | 1242265 | 22 | 446317 | 1242285 | 35 | 446066 | 1242381 | 48 | 445935 | 1242367 | 61 | 445897 | 1241978 | 74 | 446346 | 1241820 | 87 | 446819 | 1241800 | 99 | 446848 | 1241999 | 111 | 446867 | 1242133 |
| 10 | 446582 | 1242285 | 23 | 446285 | 1242290 | 36 | 446058 | 1242384 | 49 | 445933 | 1242352 | 62 | 445889 | 1241963 | 75 | 446399 | 1241716 | 88 | 446826 | 1241833 | 100 | 446851 | 1242014 | 112 | 446868 | 1242145 |
| 11 | 446553 | 1242289 | 24 | 446208 | 1242303 | 37 | 446054 | 1242393 | 50 | 445931 | 1242341 | 63 | 445898 | 1241901 | 76 | 446437 | 1241793 | 89 | 446836 | 1241848 | 101 | 446864 | 1242014 | 113 | 446867 | 1242153 |
| 12 | 446551 | 1242271 | 25 | 446210 | 1242306 | 38 | 446056 | 1242399 | 51 | 445911 | 1242348 | 64 | 446026 | 1241914 | 77 | 446436 | 1241809 | 90 | 446840 | 1241891 | 102 | 446865 | 1242045 | 114 | 446870 | 1242184 |
| [illegible] | [illegible]530 | 1242271 | 26 | 446209 | 1242310 | 39 | 445990 | 1242424 | 52 | 445906 | 1242316 | 65 | 446175 | 1241872 | 78 | 446444 | 1241869 | | | | | | | | | |